# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
អ្នកនាំពាក្យ គ.ជ.ប
លេខ ០៥៣ គ.ជ.ប

ថ្ងៃព្រហ ៧រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៨

## សេចក្តីប្រកាសព័ត៌មាន
### ថ្ងៃទី៨ នៃការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត

បន្ទាប់ពីពិនិត្យពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ ស្របតាមបទបញ្ញា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ថ្ងៃនេះ គ.ជ.ប បានសម្រេចទទួលស្គាល់ជាផ្លូវការ ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត របស់គណបក្សនយោបាយ ចំនួន ៣ គឺ ៖

- គណបក្សប្រជាជនកម្ពុជា ឈរឈ្មោះនៅ ២៥ មណ្ឌលរាជធានី ខេត្ត
- គណបក្សយុវជនកម្ពុជា ឈរឈ្មោះនៅ ១៧ មណ្ឌលរាជធានី ខេត្ត
- គណបក្សសញ្ជាតិកម្ពុជា ឈរឈ្មោះនៅ ២៥ មណ្ឌលរាជធានី ខេត្ត

**នៅព្រឹកថ្ងៃនេះ**

❖ គណបក្សប្រជាធិបតេយ្យមូលដ្ឋាន បានមកសុំពាក្យបង់ប្រាក់តម្កល់ចំនួន ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល នៅរតនាគារជាតិ។ គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ មកជម្រាប គ.ជ.ប ថា គណបក្សរបស់ខ្លួនបានតម្កល់ប្រាក់នៅរតនាគារជាតិរួចរាល់ហើយ។ គណបក្សនយោបាយចំនួន ៧ ផ្សេងទៀត ក៏បានបំពេញបែបបទតម្កល់ប្រាក់នៅរតនាគារជាតិផងដែរ រួមមាន ៖

- គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច
- គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ
- គណបក្សខ្មែរឈប់ក្រ
- គណបក្សហ៊្វុនស៊ិនប៉ិច
- គណបក្សធម្មាធិបតេយ្យ
- គណបក្សពន្លឺថ្មី ។
- គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ

❖ គណបក្សចលនាប្រជាធិបតេយ្យ បានទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ (ទ.១០០៨) ពី គ.ជ.ប ដូចគណបក្សដទៃទៀតរួមមាន ៖

- គណបក្សអំណាចខ្មែរ
- គណបក្សជនជាតិដើមប្រជាធិបតេយ្យ
- គណបក្សប្រជាធិបតេយ្យថ្មី
- គណបក្សរស្មីខេមរា
- គណបក្សកសិករ
- គណបក្សឆន្ទៈខ្មែរ
- គណបក្សខ្មែរសាធារណរដ្ឋ ។

**នៅរសៀលថ្ងៃនេះ** គណបក្សខ្មែររួបរួមជាតិ បានមកដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ នៅ គ.ជ.ប ។

គ.ជ.ប បាននិងកំពុងបំពេញបែបបទជាមួយគណបក្សនយោបាយសរុបចំនួន ២១ ៕

**ចំពោះព័ត៌មានពិស្តារ សូមទាក់ទង!**

ឯកឧត្តម **ឌឹម សុវណ្ណារុំ** សមាជិក និងជាអ្នកនាំពាក្យ គ.ជ.ប
Tel: (855)12 518 485
Email : sovannaromhy@yahoo.fr